ធ៩-៩៩-១០០ ប្រក

# ប្រកាស
# ស្តីពីការគ្រប់គ្រងអាជីវកម្មត្បូងថ្ម និងលោហធាតុមានតំលៃ

**ប្រការ ១-** កំណត់ល័ក្ខខ័ណ្ឌនៃអាជីវកម្មត្បូងថ្ម និង លោហធាតុមានតំលៃ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុងប្រការបន្តបន្ទាប់ខាងក្រោម។

**ប្រការ ២-** បុគ្គល ឬ ក្រុមបុគ្គល ដែលមានបំណងធ្វើអាជីវកម្មត្បូងថ្ម និង លោហធាតុមានតំលៃត្រូវតែមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៣-** បុគ្គលទាំងឡាយណាដែលស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មត្បូងថ្មនិងលោហធាតុមានតំលៃ ត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មានទីលំនៅ និង ទីតាំងអាជីវកម្មច្បាស់លាស់ ។

**ប្រការ ៤-** លិខិតអនុញ្ញាតអោយប្រកបអាជីវកម្មត្បូងថ្ម និង លោហធាតុមានតំលៃ ដែលចេញដោយធនាគារជាតិ នៃកម្ពុជា ត្រូវបានកំណត់ជាពីរប្រភេទ គឺ÷

- ប្រភេទ ក ចំពោះអាជីវករដែលធ្វើអាជីវកម្មត្បូងថ្ម និងលោហធាតុមានតំលៃក្នុងលក្ខណៈជា ឯកត្តជន
- ប្រភេទ ខ ចំពោះអាជីករដែលធ្វើអាជីវកម្មមានលក្ខណៈជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម និងបំពេញកាតព្វកិច្ចផ្សេងៗទៀតដូចក្រុមហ៊ុនពាណិជ្ជកម្មដទៃ ទៅតាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៥-** អាជីវករដែលបានទទួលលិខិតអនុញ្ញាតប្រភេទ"ក" មានសិទ្ធិកែច្នៃ ទិញ- លក់គ្រឿងអលង្ការ ត្បូងថ្មនិងលោហធាតុមានតំលៃគ្រប់ប្រភេទក្នុងទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជា ។

អាជីវករដែលបានទទួលលិខិតអនុញ្ញាតប្រភេទ "ខ" មានសិទ្ធិកែច្នៃ ទិញ- លក់គ្រឿងអលង្ការ ត្បូងថ្ម និង លោហធាតុមានតំលៃ និងអាចស្នើសុំពីធនាគារជាតិនៃកម្ពុជា នូវការអនុញ្ញាតនាំចេញ ឬ នាំចូលមាសដុំ និងគ្រឿងអលង្ការជាត្បូងថ្ម និង លោហធាតុមានតំលៃ ។

**ប្រការ ៦-** អាជីវករដែលបានការអនុញ្ញាតអោយប្រកបអាជីវកម្ម មានកាតព្វកិច្ចបង់ជូនធនាគារជាតិនៃកម្ពុជា នូវតម្លៃនៃសិទ្ធិធ្វើអាជីវកម្ម និង មានកាតព្វកិច្ចផ្សេងៗទៀតអនុលោមតាមប្រកាសនិងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងរាល់បទបញ្ញត្តិនិងច្បាប់ពាក់ព័ន្ធរបស់រដ្ឋ ។

**ប្រការ ៧-** អាជីវករដែលបានការអនុញ្ញាតអោយប្រកបអាជីវកម្ម ត្រូវប្រកបមុខរបររបស់ខ្លួននៅក្នុងទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដោយមានដាក់បង្ហាញនូវផ្លាកយីហោព្រមទាំងលិខិតអនុញ្ញាតរបស់ធនាគារជាតិនៃកម្ពុជា និង បិទស្លាកថ្លៃគ្រឿងអលង្ការនិមួយៗអោយបានច្បាស់លាស់ទៀតផង ។

**ប្រការ ៨-** លិខិតអនុញ្ញាតអោយប្រកបអាជីវកម្មត្បូងថ្ម និង លោហធាតុមានតំលៃ ដែលចេញដោយធនាគារជាតិនៃកម្ពុជា មានសុពលភាពសំរាប់រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃចេញអោយ ។ អាជីវករដែលចង់បន្តអាជីវកម្មរបស់ខ្លួនត្រូវដាក់ពាក្យសុំជាថ្មី ក្នុងរយៈពេល៣០ ថ្ងៃយ៉ាងយឺតបំផុត មុនថ្ងៃផុតកំណត់សុពលភាពនិមួយៗ ។

**ប្រការ ៩-** លិខិតអនុញ្ញាតអោយប្រកបអាជីវកម្មត្បូងថ្ម និង លោហធាតុមានតំលៃ អាចត្រូវដកហូតវិញបានមុនអស់សុពលភាព ក្នុងករណីដែលអាជីវករសាមីប្រព្រឹត្តល្មើសនឹងបទបញ្ជា និង របបកំណត់ផ្សេងៗ ដូចជា ÷

- មិនអនុវត្តតាមការណែនាំ និងបទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា ,
- មិនបំពេញកាតព្វកិច្ចបង់ពន្ធអាករផ្សេងៗ ជូនរដ្ឋ
- ប្រព្រឹត្ត នូវសកម្មភាពផ្សេងៗដែលផ្ទុយ នឹងច្បាប់រដ្ឋ ។

**ប្រការ ១០-** ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាពឬប្តូរទីតាំងធ្វើអាជីវកម្ម អាជីវករសាមីត្រូវធ្វើសំណើជាលាយល័ក្ខណ៍អក្សរ ដោយភ្ជាប់នូវសំណុំឯកសារពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងយឺតបំផុត៣០ថ្ងៃមុន ដើម្បីសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១១-** អាជីវករដែលប្រកបអាជីវកម្មត្បូងថ្មនិងលោហធាតុមានតំលៃ ដោយគ្មានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា នឹងត្រូវផ្តន្ទាទោសតាមមាត្រា ៧០ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១២-** ប្រកាស និងបទបញ្ជាទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៣-** អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង គ្រប់នាយកដ្ឋាន-អង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជា មានភារកិច្ចអនុវត្តរៀងៗខ្លួន តាមប្រកាសនេះ ។

**ប្រការ ១៤-** ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

ភ្នំពេញថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា **ជា ចាន់តូ**